**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១១៧/០៧ គ.ជ.ប

# គោលការណ៍

## សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជំពូកទី ៨ ស្តីពីការឃោសនាបោះឆ្នោត ។
- បានឃើញកំណត់ហេតុអង្គប្រជុំ គ.ជ.ប ជាមួយតំណាងគណបក្សនយោបាយ នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៧ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សំរាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ឬ**អ្នកគ្រប់គ្រងកម្មវិធី**) ដែលមានបំណងរៀបចំ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយគណបក្ស ដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

### I- កិច្ចសហការជាមួយ គ.ជ.ប

#### ១- ការពិគ្រោះយោបល់

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អាចពិគ្រោះយោបល់ជាមួយ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សាយ គ.ជ.ប មុននឹងចាប់ផ្តើមធ្វើកម្មវិធីនេះ លើបញ្ហាមួយចំនួនដូចជា ៖

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំធ្វើ ។
- ប្រធានបទ ឬសំនួរ ដែលត្រូវដាក់ជូនគណបក្សនយោបាយ ។
- ការសម្របសម្រួលទីតាំងប្រជុំ និង សន្តិសុខ សុវត្ថិភាព ។

#### ២- ការទទួលខុសត្រូវ

សាមីអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយ ដែលរៀបចំកម្មវិធីត្រូវទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយគោលនយោបាយនេះ ។ ហើយរាល់ការចំណាយទាំងអស់ ជាបន្ទុករបស់អ្នកគ្រប់គ្រងកម្មវិធី ។ ១

## II- កិច្ចដំណើរការកម្មវិធី

**កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ។ កម្មវិធីនេះ អាចធ្វើនៅទីកន្លែងសាធារណៈ ឬឯកជន ថ្នាក់ឃុំ សង្កាត់ ថ្នាក់ខេត្ត ក្រុង និងនៅតាមស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ផ្ទាល់ ។ ដើម្បីឱ្យដំណើរការ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា**នេះ ប្រព្រឹត្តទៅមានភាពយុត្តិធម៌សំរាប់គណបក្សនយោបាយ ដែលចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ អ្នកគ្រប់គ្រងកម្មវិធីត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

### ១/ ការត្រៀមរៀបចំមុនកម្មវិធីចាប់ដំណើរការ

- អ្នកគ្រប់គ្រងកម្មវិធី ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរអញ្ជើញតំណាងគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ជាផ្លូវការ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុង **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ។
- យោងតាមកំរិតនៃការរៀបចំនៅថ្នាក់ឃុំ សង្កាត់ ឬខេត្ត ក្រុង ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្ស ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ឬនៅក្នុងខេត្ត ក្រុងនោះ ឬគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២នេះ ។
- ក្នុងករណីអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយរៀបចំកម្មវិធីនៅតាមឃុំ សង្កាត់ ឬខេត្ត ក្រុងច្រើន ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ឬខេត្ត ក្រុង ឬនៅទូទាំងប្រទេសបានចូលរួម ។
- អ្នកគ្រប់គ្រង **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ត្រូវផ្តល់ប្រធានបទ និងសំនួរ ដែលត្រូវចោទសួរក្នុងកម្មវិធីជូនគណបក្សនយោបាយយ៉ាងតិច ៧ ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី ។
- ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញនោះហើយ តែពុំបានចាត់តំណាងរបស់ខ្លួនមកឱ្យចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថា គណបក្សនោះបោះបង់ចោលពេលវេលារបស់ខ្លួន ហើយកម្មវិធីនេះនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់ ។

### ២/ ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

- **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចធ្វើនៅទីសាធារណៈ ឬទីកន្លែងឯកជន នៅថ្នាក់ឃុំ សង្កាត់ ឬនៅថ្នាក់ខេត្ត ក្រុង ។
- **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចធ្វើនៅនឹងស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ផ្ទាល់តែម្តង ។
- **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចអញ្ជើញប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទសំនួរបាន ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន ។

### ៣/ អ្នកសម្របសម្រួលកម្មវិធី

អ្នកសម្របសម្រួល **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាព ក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព ។

៤/ ការផ្សព្វផ្សាយ កម្មវិធីសំនួរចម្លើយ ឬកម្មវិធីពិភាក្សា តាមវិទ្យុ និងទូរទស្សន៍

**កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ត្រូវអនុវត្តដូចខាងក្រោម ៖

- **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** ដែលធ្វើនៅតាមឃុំ សង្កាត់ណា អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលមានស្ថានីយ៍នៅក្នុងខេត្ត ក្រុង នៃឃុំ សង្កាត់នោះ ។
- **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អាចផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍នៅថ្នាក់ជាតិបាន លុះត្រាតែមានការចូលរួមគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជាផ្លូវការទាំងអស់ក្នុងខេត្ត ក្រុងណាមួយ ឬទូទាំងប្រទេស ទើបអាចផ្សព្វផ្សាយបាន ។

## III- គោលការណ៍ច្បាប់

- អ្នកគ្រប់គ្រងកម្មវិធីសំនួរចម្លើយ ឬពិភាក្សាអាចផ្តល់ម៉ោងដល់គណបក្សនយោបាយក្នុងការឆ្លើយសំនួរផ្អែកតាមគោលការណ៍ពីរយ៉ាង ៖

  ១-គោលការណ៍ស្មើភាព

  ២-គោលការណ៍បន្ថែមរយៈពេល ១០ % នៃម៉ោងសរុបរួមរបស់គណបក្សនយោបាយនីមួយៗ តាមគោលការណ៍ស្មើភាពសំរាប់គណបក្ស ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតលើសពី ២/៣ (ពីរភាគបី) ឃុំ សង្កាត់ នៃខេត្ត ក្រុងណាមួយ ឬចាប់ពី ១០០០ (មួយពាន់) ឃុំ សង្កាត់ឡើង នៃឃុំ សង្កាត់ ទូទាំងប្រទេស ។

- អ្នកគ្រប់គ្រង **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយរបស់គណបក្សត្រូវតែអព្យាក្រឹត និងមិនលំអៀង ។
- ការផ្សព្វផ្សាយ **កម្មវិធីសំនួរចម្លើយ ឬពិភាក្សា** អំពីគោលនយោបាយគណបក្ស ពុំត្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោត ក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី ។
- រាល់កិច្ចដំណើរការទាំងអស់របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជា និងនីតិវិធី គ.ជ.ប ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម_សួស្តី